# វេទិកាសាធារណៈ
# ស្តីពី
# យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ
# ២០១៥-២០១៨

**រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# មាតិកា

១. សាវតារ

២. សមិទ្ធផលធំៗនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨

៣. ការគ្រប់គ្រង និងតាមដានហានិភ័យបំណុល

៤. ចក្ខុវិស័យនៃការគ្រប់គ្រងបំណុលសាធារណៈ

៥. បញ្ហាប្រឈមនៃការគ្រប់គ្រងបំណុលសាធារណៈ

៦. បច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨

# ១. សាវតារ (១/៩)

- នៅមុនឆ្នាំ២០១១ ការគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា ត្រូវបានអនុវត្តដោយគោរពយ៉ាងម៉ឺងម៉ាត់ទៅតាមគោលការណ៍គន្លឹះទាំង ០៤ របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលរួមមាន៖

  (១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

  (២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន និងលក្ខខណ្ឌអនុគ្រោះខ្ពស់

  (៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពកំណើន និងបង្កើនផលិតភាពសេដ្ឋកិច្ច

  (៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

- បើទោះមិនមានយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ តែគោលការណ៍ទាំង ០៤ នេះ ត្រូវបានប្រកាន់យកតាំងពីឆ្នាំ១៩៩៣-១៩៩៤ មកម្ល៉េះ។

# ១. សាធារណៈ (២/៩)

## អនុបាតសន្និធិបំណុលធៀបនឹង ផសស



# ១. សាចតារ (៣/៩)

## អនុបាតសន្និធិបំណុលធៀបនឹង ការនាំចេញ



# ១. សាធារ (៤/៩)

## អនុបាតសន្និធិបំណុលធៀបនឹង ចំណូលថវិកាជាតិ



# ១. សារពើពន្ធ ( ៥/៩ )



អនុបាតសេវាបំណុលធៀបនឹង ការនាំចេញ
%
25
20
15
10
5
0
អនុបាតសេវាបំណុលធៀបនឹង ការនាំចេញ÷ ១,៣%
ធៀបអនុបាតគោល ២០% (ឆ្នាំ២០១៥)
អនុបាតសេវាបំណុល
អនុបាតគោល
1994
1995
1996
1997
1998
1999
2000
2001
2002
2003
2004
2005
2006
2007
2008
2009
2010
2011
2012
2013
2014
2015 e
2016 p

# ១. សារពើពន្ធ (៦/៩)


អនុបាតសេវាបំណុលធៀបនឹង ចំណូលថវិកាជាតិ
%
35
30
25
20
15
10
5
0
អនុបាតសេវាបំណុលធៀបនឹង ចំណូលថវិកាជាតិ÷ ៥,៧%
ធៀបអនុបាតគោល ២០% (២០១៥)
អនុបាតសេវាបំណុល
អនុបាតគោល
1994
1995
1996
1997
1998
1999
2000
2001
2002
2003
2004
2005
2006
2007
2008
2009
2010
2011
2012
2013
2014
2015 e
2016 p

# ១. សាវតារ (៧/៩)

- ដោយបន្តប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះទាំង ០៤ ជាផែនទីចង្អុលទិស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨ ដែលជាយុទ្ធសាស្ត្រគ្រប់គ្រងបំណុលលើកទី១ របស់កម្ពុជា ដើម្បីដាក់ឆ្លងគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈពិភាក្សា និងយល់ព្រម មុននឹងសុំការសម្រេចពីសម្តេចតេជោនាយករដ្ឋមន្ត្រី។

- យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨ នេះ ត្រូវបានអនុម័ត កាលពី **ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១២** និងបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នា**ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២**។

- យុទ្ធសាស្ត្រនេះ បានកំណត់ទំហំនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ២០១១-២០១៨ ក្នុងរង្វង់ពី **៤០០ លាន** ទៅ **៧០០ លានអេសដេអ៊ែរ** ក្នុងមួយឆ្នាំ និងបានដាក់ចេញនូវវិធានការគោលនយោបាយ ០៨ ចំណុចផ្សេងទៀត ដើម្បីធានាបាននូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ដំណាក់កាលទី២។

# ១. សាវតារ (៨/៩)

វិធានការគោលនយោបាយទាំង ០៨ ចំណុច មានដូចខាងក្រោម៖

១) បន្តប្រើប្រាស់ឥណទានសម្បទានសម្រាប់វិនិយោគមូលធនលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងការទ្រទ្រង់ចីរភាពកំណើនក្នុងរយៈពេលវែង

២) បន្តពង្រឹងយន្តការគ្រប់គ្រង និងអនុវត្តគម្រោងវិនិយោគសាធារណៈឱ្យមានប្រសិទ្ធភាពខ្ពស់

៣) បន្តរក្សាកម្រិតសម្បទានឥណទានឱ្យខ្ពស់តាមដែលអាចធ្វើបាន ស្របតាមបរិការណ៍ជាក់ស្ដែងនៃការលូតលាស់របស់សេដ្ឋកិច្ចជាតិ

៤) បន្តជំរុញអនុវត្តគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងវិស័យសំខាន់ៗ សំដៅរក្សាចីរភាពកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ក្នុងរង្វង់ ៦% - ៧% ក្នុងមួយឆ្នាំ និងចំណូលថវិកាជាតិខ្ពស់បំផុត

៥) បន្តអនុវត្តគោលការណ៍មជ្ឈការនៃការគ្រប់គ្រងបំណុលសាធារណៈ

៦) បន្តពង្រឹងការកៀរគរហិរញ្ញប្បទានឥតសំណង និងពីប្រភពហិរញ្ញប្បទានផ្សេងទៀត សម្រាប់បម្រើឱ្យតម្រូវការវិនិយោគសាធារណៈ

៧) ពង្រឹងការតាមដានត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធក្នុងវិស័យពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ

៨) ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងវិស័យពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ។

# ១. សាវតារ (៩/៩)

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានត្រួតពិនិត្យលើការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨ និងបានធ្វើបច្ចុប្បន្នកម្មឱ្យទៅជាយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៥-២០១៨។
- យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៥-២០១៨ ត្រូវបានពិភាក្សានិងយល់ព្រមដោយគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ និងអនុម័តដោយសម្តេចតេជោនាយករដ្ឋមន្ត្រី កាលពី**ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥** និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពី**ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥**។

# ២. សមិទ្ធផលធំៗនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១១-២០១៨

សមិទ្ធផលធំៗ ដែលសម្រេចបានក្នុងរយៈពេលនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨ រួមមាន៖

១. ការគ្រប់គ្រងបាននូវទំហំនៃការខ្ចីថ្មីមិនឱ្យលើសពិដានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ

២. ការសម្រិតសម្រាំងយកតែឥណទានដែលមានកម្រិតសម្បទានខ្ពស់

៣. ការប្រើប្រាស់ឥណទានសម្បទានចំគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល

៤. ការរក្សាបាននូវចីរភាពបំណុលសាធារណៈ និងការកម្រិតហានិភ័យបំណុលឱ្យនៅទាប

៥. ការកើនឡើងជាលំដាប់នៃពិន្ទុសូចនាករគោលនយោបាយបំណុល

ចំណុចទាំង ៥ នេះ នឹងមានលម្អិតក្នុង Slides ខាងក្រោម។

# ២.១. ការគ្រប់គ្រងបាននូវទំហំនៃការខ្ចីថ្មីមិនឱ្យលើសពិដានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ

## ការខ្ចីឥណទានសម្បទានក្នុងឆ្នាំ២០១១-២០១៤

| ឆ្នាំ | ច្បាប់អនុញ្ញាត (ជាលានអេសដេអ៊ែរ) | អនុវត្ត | | អនុវត្តធៀបនឹងច្បាប់ |
|---|---|---|---|---|
| | | (ជាលានអេសដេអ៊ែរ) | (ជាលានដុល្លារអាមេរិក) | |
| ២០១១ | ៤០០ | ៣៥៤,៩ | ៥៤៣ | ៨៨,៧% |
| ២០១២ | ៧០០ | ៦៨៦,២ | ១ ០៥៤ | ៩៨,០% |
| ២០១៣ | ៦០០ | ៥១៩ | ៨០៣ | ៨៦,៥% |
| ២០១៤ | ៦០០ | ៥១០,៩ | ៧៤៤ | ៨៥,២% |
| សរុប | ២ ៣០០ | ២ ០៧១ | ៣ ១៤៤ | ៩០% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ២.២. ការសម្រិតសម្រាំងយកតែឥណទានដែលមានកម្រិតសម្បទានខ្ពស់

| លក្ខខណ្ឌនៃឥណទាន | |
|---|---|
| អត្រាការប្រាក់ | ០ - ២% ក្នុងមួយឆ្នាំ |
| រយៈពេលសង | ២០ - ៤០ ឆ្នាំ |
| រយៈពេលអនុគ្រោះ | ៧ - ១៥ ឆ្នាំ |
| ធាតុអំណោយប្រមាណពី ៣៥% ឡើងទៅ | |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ២.៣. ការប្រើប្រាស់ឥណទានសម្បទានចំគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល

## ការខ្ចី និងការដកសាច់ប្រាក់តាមវិស័យ ក្នុងឆ្នាំ២០១១-២០១៤

*ឯកតា៖ លានដុល្លារអាមេរិក*

| | ២០១១ | ២០១២ | ២០១៣ | ២០១៤ | សរុប |
|---|---|---|---|---|---|
| ក- ការខ្ចីឥណទានសម្បទានសរុប | ៥៤៣ | ១ ០៥៤ | ៨០៣ | ៧៤៤ | ៣ ១៤៤ |
| -វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ៥០៨ | ១ ០២១ | ៦២៨ | ៦៦៩ | ២ ៨២៦ |
| ភាគរយ | ៩៤% | ៩៧% | ៧៨% | ៩០% | ៩០% |
| -វិស័យផ្សេងទៀត | ៣៥ | ៣៣ | ១៧៥ | ៧៥ | ៣១៨ |
| ភាគរយ | ៦% | ៣% | ២២% | ១០% | ១០% |
| ខ- ការដកសាច់ប្រាក់សរុប | ៥៣១ | ៦៦០ | ៦០៩ | ៦៤៣ | ២ ៤៤៣ |
| -វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ៤២៣ | ៥៦៩ | ៤៦៨ | ៦០៤ | ២ ០៦៤ |
| ភាគរយ | ៨០% | ៨៦% | ៧៧% | ៩៤% | ៨៤% |
| -វិស័យផ្សេងទៀត | ១០៨ | ៩១ | ១៤១ | ៣៩ | ៣៧៩ |
| ភាគរយ | ២០% | ១៤% | ២៣% | ៦% | ១៦% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ២.៤. ការរក្សាបាននូវចីរភាពបំណុលសាធារណៈ និងការកម្រិតហានិភ័យបំណុលឱ្យនៅទាប

## អនុបាតបំណុលក្រៅប្រទេស ២០១១-២០១៤

| | អនុបាតគោល | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|
| តម្លៃបច្ចុប្បន្ននៃបំណុលក្រៅប្រទេស | | | | | |
| % នៃ ផសស | ៤០ | ១៩,៧ | ២១,៣ | ២៣,១ | ២៣,១ |
| % នៃការនាំចេញ | ១៥០ | ៣៤,៤ | ៣៤,៩ | ៣៥,៦ | ៣៤,៥ |
| % នៃចំណូលថវិកាជាតិ | ២៥០ | ១៥៤,១ | ១៤១,៦ | ១៦១,២ | ១៥១,៧ |
| សេវាបំណុល | | | | | |
| % នៃការនាំចេញ | ២០ | ០,៩ | ១,០ | ១,០ | ១,០ |
| % នៃចំណូលថវិកាជាតិ | ២០ | ៤,១ | ៣,៩ | ៤,៣ | ៤,៦ |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ២.៥. ការកើនឡើងជាលំដាប់នៃពិន្ទុសូចនាករ គោលនយោបាយបំណុល

## ពិន្ទុនៃសូចនាករគោលនយោបាយបំណុលរបស់កម្ពុជា ឆ្នាំ២០០៥-២០១៤

| ឆ្នាំ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ |
|---|---|---|
| ២០០៥ | ៣,៥ | ៣,៥ |
| ២០០៦ | ៣,៥ | ៣,៥ |
| ២០០៧ | ៤,០ | ៣,៥ |
| ២០០៨ | ៤,០ | ៣,៥ |
| ២០០៩ | ៤,០ | ៣,៥ |
| ២០១០ | ៤,០ | ៣,៥ |
| ២០១១ | ៤,៥ | ៣,៥ |
| ២០១២ | ៥,០ | ៤,០ |
| ២០១៣ | ៥,០ | ៤,០ |
| ២០១៤ | ៥,០ | ៤,០ |

*ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ*

# ៣. ការគ្រប់គ្រង និងតាមដានហានិភ័យបំណុល

១. ហានិភ័យហិរញ្ញប្បទាននៃគម្រោង ឬហានិភ័យបុនហិរញ្ញប្បទាន ( Project Funding Risk )

២. ហានិភ័យទីផ្សារ ( Market Risk )

៣. ហានិភ័យឥណទាន ( Credit Risk )

៤. ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល ( Liquidity Risk )

៥. ហានិភ័យប្រតិបត្តិការ ( Operational Risk )

៦. ហានិភ័យថវិកា ( Fiscal Risk )

៧. កាតព្វកិច្ចបំណុលដោយថាហេតុ ( Contingent Liabilities )

*( ហានិភ័យទាំងនេះ មានលម្អិតដូចក្នុង Slides បន្ទាប់ )*

# ៣.១. ហានិភ័យហិរញ្ញប្បទាននៃគម្រោង ឬហានិភ័យមុនហិរញ្ញប្បទាន

- បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ (ចាស់ និងថ្មី)




- បានប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍គ្រឹះសំខាន់៖ ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព។

➢ ***ជារួម ក្នុងឆ្នាំ២០១១-២០១៤ កន្លងទៅ ពុំមានហានិភ័យនេះទេ។***

# ៣.២. ហានិភ័យទីផ្សារ (១/២)

## ៣.២.១. ហានិភ័យរូបិយប័ណ្ណ

រូបិយប័ណ្ណបំណុលនៃបំណុលសាធារណៈក្រៅប្រទេសរបស់កម្ពុជា២០១០-២០១៤




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ៣.២. ហានិភ័យទីផ្សារ (២/២)

## ៣.២.២. ហានិភ័យអត្រាការប្រាក់

- ឥណទានសម្បទានដែលរាជរដ្ឋាភិបាលបានខ្ចី សុទ្ធសឹងជាឥណទានដែលមានអត្រាការប្រាក់ថេរ (Fixed Rate)។
- បានចាត់វិធានការបំប្លែងពីឥណទានដែលមានអត្រាការប្រាក់ប្រែប្រួល ទៅជាអត្រាការប្រាក់ថេរ។
  - ឧទាហរណ៍៖ បំប្លែងឥណទានផ្តល់ដោយ AFD ឱ្យទៅជាឥណទានដែលមានអត្រាការប្រាក់ថេរ ដោយកម្រិតឱ្យនៅចន្លោះពី **0,២៥%** ទៅ **២%** ក្នុងមួយឆ្នាំ។

➢ *ជារួម កម្ពុជាពុំមានហានិភ័យនេះទេ។*

# ៣.៣. ហានិភ័យឥណទាន

- កន្លងមក ដើម្បីជួយពង្រឹងស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសសាធារណៈមួយចំនួន ដែលបានខ្ចីឥណទានពីរដ្ឋ កសហវ បានផ្តល់ភាពអនុគ្រោះ តាមរយៈការពន្យារពេលទូទាត់សេវាបំណុល និងបន្ថយអត្រាការប្រាក់ តែបានធ្វើឱ្យចំណូលសេវាបំណុលធ្លាក់ចុះទាបជាងផែនការដែលបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។
- ជាវិធានការដើម្បីបង្ការ ឬបញ្ចៀសហានិភ័យនេះ កសហវ បានរៀបចំ និងដាក់ឱ្យអនុវត្តប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការផ្តល់ឥណទានដល់សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ នីតិបុគ្គលសាធារណៈដទៃទៀត និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥។

# ៣.៤. ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (១/២)

## កម្មវិធីទូទាត់សេវាបំណុលឆ្នាំ២០១៤




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ៣.៤. ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (២/២)

## ព្យាករណ៍កម្មវិធីទូទាត់សេវាបំណុលឆ្នាំ២០១៥-២០២០




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ៣.៥. ហានិភ័យប្រតិបត្តិការ (១/២)

- បានរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។
- បានជំរុញ និងចរចាជាមួយបណ្តាដៃគូអភិវឌ្ឍន៍ឱ្យចូលរួមអនុវត្តប្រព័ន្ធរបស់ប្រទេស ក្រោមក្របខ័ណ្ឌនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោង។
- បានផ្តល់វគ្គបណ្តុះបណ្តាលពេញលេញជូនមន្ត្រីអនុវត្តគម្រោងក្រោមហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។
- បានកែសម្រួលនីតិវិធីប្រតិបត្តិការក្នុងការទូទាត់ និងប្រមូលចំណូលសេវាបំណុល តាមរយៈការធ្វើប្រតិភូកម្មសិទ្ធិចុះហត្ថលេខាលើអាណត្តិបើកប្រាក់ និងលិខិតទារសេវាបំណុល។
- បានរៀបចំប្រព័ន្ធផ្តល់ដំណឹងស្វ័យប្រវត្តិអំពីកម្មវិធីទូទាត់ និងទារសេវាបំណុល (Alert System) នៅក្នុងប្រព័ន្ធ Ms. Excel។

# ៣.៥. ហានិភ័យប្រតិបត្តិការ (២/២)

- បានធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុលពី DMFAS 5.3 ទៅ DMFAS 6.0។
- បានបង្កើតក្រុមការងារកត់ត្រា និងផ្ទៀងផ្ទាត់ទិន្នន័យបំណុល (Internal Control Cell)។
- បានបង្កើតប្រព័ន្ធគ្រប់គ្រង ថែរក្សា និងផ្ទុកទិន្នន័យ (Back Up System)។
- បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ និងនីតិវិធីប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ។

➢ *ជារួម ក្នុងឆ្នាំ២០១១-២០១៤ កន្លងទៅ ពុំមានហានិភ័យធ្ងន់ធ្ងរកើតឡើងទេ។*

# ៣.៦. ហានិភ័យថវិកា

- បានខិតខំសម្រិតសម្រាំងយកតែឥណទានណាដែលមានកម្រិតសម្បទានខ្ពស់ ដោយមានធាតុអំណោយចាប់ពី **៣៥ ភាគរយ** ឡើងទៅ។
- កំណើន ផសស និងចំណូលថវិកាជាតិ សុទ្ធតែសម្រេចបានតាម ឬលើសគោលដៅកំណត់។ *

➢ ***ជារួម ពុំមានការប៉ះពាល់ដល់ពិដាននៃការខ្ចីប្រចាំឆ្នាំទេ។***

**លើកលែងតែនៅឆ្នាំ២០១១ ដែលចំណូលថវិកាជាតិសម្រេចបានត្រឹមកម្រិត ១៣,២ ភាគរយ នៃ ផសស។*

# ៣.៧. កាតព្វកិច្ចបំណុលដាយថាហេតុ ( ១/៥ )

ជាទូទៅ កាតព្វកិច្ចបំណុលជាយថាហេតុអាចកើតចេញពីប្រភព ឬ កត្តាមួយចំនួនដូចខាងក្រោម៖

1. វិស័យធនាគារនិងហិរញ្ញវត្ថុ ( Banking and Financial Sector )
2. ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈសហគ្រាសសាធារណៈនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
3. ការធានារបស់រដ្ឋ ( Guarantee )

# ៣.៧. ភាតព្វកិច្ចបំណុលជាយថាហេតុ (២/៥)

## ៣.៧.១. វិស័យធនាគារនិងហិរញ្ញវត្ថុ

- ការរក្សាបាននូវស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច
- កិច្ចសហការរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តវិធានការម៉ឹងម៉ាត់ និងប្រយ័ត្នប្រយែងលើការរៀបចំ និងអនុវត្តគោលនយោបាយរូបិយវត្ថុតាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិនានា ដូចជា៖ (១) ប្រកាសស្តីពីអនុបាតក្របខ័ណ្ឌសន្ទនីយភាព, (២) ប្រកាសស្តីពីការត្រួតពិនិត្យហានិភ័យនៃឥណទានធំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, (៣) ប្រកាសស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ, (៤) ប្រកាសស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ល។

- ➢ *ជារួម កម្ពុជាពុំមានកាតព្វកិច្ចបំណុលជាយថាហេតុក្នុងវិស័យនេះទេ។*

# ៣.៧. ភាគពុកិច្ចបំណុលជាយថាហេតុ (៣/៥)

## ៣.៧.២. ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុដោយប្រយ័ត្នប្រយែង និងបាន ដាក់ចេញនូវច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានមួយចំនួន ដូចជា៖
  - ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
  - ច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
  - សារាចរអនុវត្តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងវិធានការពាក់ព័ន្ធជាធរមាន

# ៣.៧. ភាតព្វកិច្ចបំណុលជាយថាហេតុ ( ៤/៥ )

## ៣.៧.៣. ការធានារបស់រដ្ឋ ( ១/២ )

ការធានារបស់រដ្ឋចំពោះគម្រោង PPP/BOT/BOO ក្នុងវិស័យអគ្គិសនី

| ល.រ | ប្រភេទគម្រោង | ចំនួន | រូបភាពធានា | |
|---|---|---|---|---|
| | | | ទូទាត់ | ទិញគម្រោង |
| ១ | វារីអគ្គិសនី | ០៧ | ករណី EDC គ្មានលទ្ធភាពទូទាត់ថ្លៃទិញអគ្គិសនី | ករណីគម្រោងមិនអាចដំណើរការបាន ដោយសារៈ<br>-ប្រធានសក្តិនយោបាយ<br>-ក្រុមហ៊ុនវិនិយោគក្ស័យធន |
| ២ | រោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម | ០៣ | | |
| ៣ | ខ្សែបញ្ជូនអគ្គិសនី | ០២ | ករណី EDC គ្មានលទ្ធភាពទូទាត់ថ្លៃឈ្នួលខ្សែបញ្ជូន | |
| ៤ | នាំចូលអគ្គិសនីពីប្រទេសជិតខាង | ០១ | ករណី EDC គ្មានលទ្ធភាពទូទាត់ថ្លៃទិញអគ្គិសនី | - |

*ប្រភព៖ អគ្គិសនីកម្ពុជា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ៣.៧. ភាតព្វកិច្ចបំណុលជាយថាហេតុ ( ៥/៥ )

## ៣.៧.៣. ការធានារបស់រដ្ឋ ( ២/២ )

### ពិដាននៃការធានារបស់ប្រទេសមួយចំនួន

| ល.រ | ឈ្មោះប្រទេស | បរិយាយ | ពិដាន |
|---|---|---|---|
| ១- | ឥណ្ឌា | ការធានាប្រចាំឆ្នាំ | ០,៥% នៃ ផសស |
| ២- | កូរ៉េខាងត្បូង | ការធានាប្រចាំឆ្នាំ | ២% នៃ ផសស |
| ៣- | ចក្រភពអង់គ្លេស | ការធានាប្រចាំឆ្នាំ | ២% នៃ ផសស |
| ៤- | ប៉ាគីស្ថាន | ការធានា, ការផ្តល់ឥណទានពីរដ្ឋ, និង ការបោះផ្សាយមូលបត្ររដ្ឋ ប្រចាំឆ្នាំ | ២% នៃ ផសស |
| ៥- | ឥណ្ឌូនេស៊ី | ការធានាប្រចាំឆ្នាំ | ២,៥% នៃ ផសស |
| ៦- | លីទុយអានី | ការធានាប្រចាំឆ្នាំ | ៣% នៃ ផសស |
| ៧- | ម៉ាសេដូនី | ការធានាប្រចាំឆ្នាំ | ១០% នៃ ផសស |
| ៨- | សាធារណរដ្ឋស៊ែប | ការធានាប្រចាំឆ្នាំ | ១៥% នៃ ផសស |
| ៩- | ប៉ូឡូញ | ការធានា និងការបោះផ្សាយមូលបត្ររដ្ឋ | ១៨% នៃ ផសស |
| ១០- | ថៃ | ការធានា និងការខ្ចីសម្រាប់ឱ្យខ្ចីបន្តប្រចាំឆ្នាំ | ២០% នៃចំណាយថវិកាប្រចាំឆ្នាំ |

*ប្រភព៖ ការស្រាវជ្រាវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

# ៤. ចក្ខុវិស័យនៃការគ្រប់គ្រងបំណុលសាធារណៈ

- ជាចក្ខុវិស័យសម្រាប់រយៈពេលមធ្យម និងវែង រាជរដ្ឋាភិបាលនឹងពង្រីកវិសាលភាពនៃការគ្រប់គ្រងបំណុល ឱ្យគ្របដណ្តប់លើបំណុលរួមរបស់ជាតិទាំងមូល ដោយត្រូវបញ្ចូលទាំងបំណុលរបស់វិស័យឯកជន ជាពិសេស បំណុលក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច។
- ទោះជាយ៉ាងនេះក្តី ក្នុងរយៈពេលមធ្យម និងវែង រាជរដ្ឋាភិបាលនឹងនៅតែប្រកាន់គោលនយោបាយមិនផ្តល់ការធានាលើបំណុលរបស់វិស័យឯកជនទេ។

# ៥. បញ្ហាប្រឈមនៃការគ្រប់គ្រងបំណុលសាធារណៈ

❖ បញ្ហាប្រឈមដែលកំពុងបន្តជះឥទ្ធិពលលើការគ្រប់គ្រងបំណុលសាធារណៈ ទាំងក្នុងដំណាក់កាលបច្ចុប្បន្ន និងទាំងក្នុងពេលអនាគត មានដូចខាងក្រោម៖

១. ភាពរឹងស្ងួតនៃហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់

២. លទ្ធភាពនៃការធ្លាក់ចុះអតិរេកចរន្តសម្រាប់ចំណាយគម្រោងវិនិយោគផ្ទាល់

៣. ប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

៤. ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចកើតចេញ ពីការធានារបស់រដ្ឋលើគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) និង ពីវិស័យធនាគារនិងហិរញ្ញវត្ថុ

# ៦. បច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨

❖ លក្ខខណ្ឌតម្រូវក្នុងការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុល សាធារណៈ២០១៥-២០១៨៖

- ការពិនិត្យឃើញសភាពការណ៍វិវឌ្ឍថ្មីៗក្នុងវិស័យគ្រប់គ្រងបំណុលសាធារណៈរបស់កម្ពុជា, តំបន់, និងសកលលោក។
- មាត្រា៦៧ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។
- មាត្រា២៧ នៃអនុក្រឹត្យស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ។

# ៦.១. គោលដៅ និងវិសាលភាព

- យុទ្ធសាស្ត្រនេះ មានគោលដៅកំណត់នូវ វិធានការគោលនយោបាយសំដៅពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាពក្នុងរយៈពេលវែង។

- យុទ្ធសាស្ត្រនេះ មានវិសាលភាពគ្របដណ្តប់លើរាល់ប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈរបស់រដ្ឋ និងមិនគ្របដណ្តប់លើបំណុលរបស់វិស័យឯកជនទេ។ ក្នុងរយៈពេលមធ្យម និងវែង វិសាលភាពនេះនឹងត្រូវបានពង្រីក ឱ្យគ្របដណ្តប់បំណុលរបស់វិស័យឯកជនផងដែរ។

# ៦.២. គោលបំណង

❖ យុទ្ធសាស្ត្រនេះ មានគោលបំណងធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្នុងការគ្រប់គ្រងបំណុលសាធារណៈ សំដៅបន្តរក្សាចីរភាពបំណុលសាធារណៈរយៈពេលវែង និងកម្រិតហានិភ័យបំណុលឱ្យនៅទាប ដោយធានាបាននូវសង្គតិភាព និងភាពប្រទាក់ក្រឡាគ្នាជាមួយឯកសារយុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធនានា រួមមាន៖ ១) យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី៣, ២) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, ៣) គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, ៤) គោលនយោបាយថវិកា, ៥) គោលនយោបាយរូបិយវត្ថុ, ៦) យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០, ៧) គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥, និង ៨) យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ល។

# ៦.៣. ការវិភាគចីរភាពបំណុល (១/៦)

**សេណារីយ៉ូនៃការខ្ចីថ្មីបន្ថែម៖**

- **សេណារីយ៉ូទី១៖** ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី ៦០០ លានអេសដេអ៊ែរសម្រាប់ឆ្នាំ ២០១៥ និង ៧០០ លាន ទៅ ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០១៦-២០១៨។
- **សេណារីយ៉ូទី២៖**ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ពី ៨០០ លាន ទៅ ១ ០០០ លាន អេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៥-២០១៨។

# ៦.៣. ការវិភាគចីរភាពបំណុល តាមសេណារីយ៉ូទី១ (មិនគិតបំណុលចាស់) ២/៦

ទំហំនៃការខ្ចីថ្មី៖ ក្នុងរង្វង់ ៦០០ លានអេដេអ៊ែរ (ឆ្នាំ២០១៥) និង ៧០០ លាន - ៨០០ លានអេសដេអ៊ែរ/ឆ្នាំ (ឆ្នាំ២០១៦-២០១៨)

ក- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹង ផសស




ខ- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងការនាំចេញ




គ- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងចំណូលថវិកាជាតិ




ឃ- សេវាបំណុលធៀបនឹងការនាំចេញ




ង- សេវាបំណុលធៀបនឹងចំណូលថវិកាជាតិ




Baseline
មូលដ្ឋាន (មានការខ្ចីថ្មី)

Threshold
អនុបាតគោល

Historical scenario
ប្រវត្តិសាស្ត្រ (គ្មានការខ្ចីថ្មី)

Customized Scenario
ផសស និងចំណូលថវិកាជាតិមានកំណើនទាប

Most extreme shock
វេទយិតភាព (ការធ្លាក់ចុះការនាំចេញ)

# ៦.៣. ការវិភាគចីរភាពបំណុល តាមសេណារីយ៉ូទី១
# (គិតទាំងបំណុលចាស់) ៣/៦

## ទំហំនៃការខ្ចីថ្មី៖ ក្នុងរង្វង់ ៦០០ លានអេដេអ៊ែរ (ឆ្នាំ២០១៥) និង ៧០០ លាន - ៨០០ លានអេសដេអ៊ែរ/ឆ្នាំ (ឆ្នាំ២០១៦-២០១៨)

ក- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹង ផសស




ខ- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងការនាំចេញ




គ- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងចំណូលថវិកាជាតិ




ឃ- សេវាបំណុលធៀបនឹងការនាំចេញ




ង- សេវាបំណុលធៀបនឹងចំណូលថវិកាជាតិ




Baseline
មូលដ្ឋាន (មានការខ្ចីថ្មី)

Threshold
អនុបាតគោល

Historical scenario
ប្រវត្តិសាស្ត្រ (គ្មានការខ្ចីថ្មី)

Customized Scenario
ផសស និងចំណូលថវិកាជាតិមានកំណើនទាប

Most extreme shock
វេទយិតភាព (ការធ្លាក់ចុះការនាំចេញ)

# ៨.៦.៥. ការវិភាគចីរភាពបំណុល តាមសេណារីយ៉ូទី២ (មិនគិតបំណុលចាស់) ៤/៦

## ទំហំនៃការខ្ចីថ្មី៖ ក្នុងរង្វង់ ៨០០ លាន - ១ ០០០ លានអេសដេអ៊ែរ/ឆ្នាំ សម្រាប់ឆ្នាំ២០១៥-២០១៨

ក- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹង ផសស




ខ- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងការនាំចេញ




គ- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងចំណូលថវិកាជាតិ




ឃ- សេវាបំណុលធៀបនឹងការនាំចេញ




ង- សេវាបំណុលធៀបនឹងចំណូលថវិកាជាតិ




Baseline
មូលដ្ឋាន (មានការខ្ចីថ្មី)

Threshold
អនុបាតគោល

Historical scenario
ប្រវត្តិសាស្ត្រ (គ្មានការខ្ចីថ្មី)

Customized Scenario
ផសស និងចំណូលថវិកាជាតិមានកំណើនទាប

Most extreme shock
វេទយិតភាព (ការធ្លាក់ចុះការនាំចេញ)

# ៨.៦.៧. ការវិភាគចីរភាពបំណុល តាមសេណារីយ៉ូទី២ (គិតទាំងបំណុលចាស់) ៥/៦

## ទំហំនៃការខ្ចីថ្មី៖ ក្នុងរង្វង់ ៨០០ លាន - ១ ០០០ លានអេសដេអ៊ែរ/ឆ្នាំ សម្រាប់ឆ្នាំ២០១៥-២០១៨

ក- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹង ផសស




ខ- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងការនាំចេញ




គ- តម្លៃបច្ចុប្បន្ននៃបំណុលធៀបនឹងចំណូលថវិកាជាតិ




ឃ- សេវាបំណុលធៀបនឹងការនាំចេញ




ង- សេវាបំណុលធៀបនឹងចំណូលថវិកាជាតិ




Baseline
មូលដ្ឋាន (មានការខ្ចីថ្មី)

Threshold
អនុបាតគោល

Historical scenario
ប្រវត្តិសាស្ត្រ (គ្មានការខ្ចីថ្មី)

Customized Scenario
ផសស និងចំណូលថវិកាជាតិមានកំណើនទាប

Most extreme shock
វេទយិតភាព (ការធ្លាក់ចុះការនាំចេញ)

# ៦.៣. ការវិភាគចីរភាពបំណុល (៦/៦)

- លទ្ធផលនៃការវិភាគចីរភាពបំណុល បង្ហាញថា៖
  - សេណារីយ៉ូទី១៖ មាន "**ចីរភាព**" និងប្រឈមនូវ "**ហានិភ័យកម្រិតទាប**" ទាំងករណីគិត និងមិនគិតបញ្ចូលបំណុលចាស់ ឬបំណុលមរតកកំពុងដោះស្រាយ។
  - សេណារីយ៉ូទី២៖ មាន "**ចីរភាព**" និងប្រឈមនូវ "**ហានិភ័យកម្រិតមធ្យម**" ទាំងករណីគិត និងមិនគិតបញ្ចូលបំណុលចាស់ ឬបំណុលមរតកកំពុងដោះស្រាយ។

➢ កម្ពុជាមានសមត្ថភាពខ្ចីឥណទានសម្បទានថ្មីបន្ថែមក្នុងរង្វង់ ៦០០ លានអេសដេអ៊ែរ សម្រាប់ឆ្នាំ២០១៥ និង ៧០០ លាន ទៅ ៨០០ លានអេសដេអ៊ែរ ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ ២០១៦-២០១៨ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែង។

# ៦.៤. វិធានការគោលនយោបាយសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ (១/៤)

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៥-២០១៨ បានដាក់ចេញនូវវិធានការគោលនយោបាយក្នុងការគ្រប់គ្រងបំណុលសាធារណៈ ចំនួន ០៩ ចំណុចដូចខាងក្រោម៖

១. កំណត់ទំហំនៃការខ្ចីថ្មីបន្ថែមក្នុងរង្វង់ **៦០០ លានអេសដេអ៊េរ** សម្រាប់ឆ្នាំ២០១៥ និងក្នុងរង្វង់ពី **៧០០ លាន** ទៅ **៨០០ លានអេសដេអ៊េរ** ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំ២០១៦-២០១៨ ទៅតាមបរិការណ៍នៃគោលនយោបាយថវិកា និងវិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា។

សម្រាប់ឆ្នាំ២០១៥-២០១៨ ជារួម រាជរដ្ឋាភិបាលនឹងមិនបោះផ្សាយមូលបត្ររដ្ឋ ឬសញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ដែលជាឧបករណ៍បំណុលថ្មីទេ តែអាចសាកល្បងបោះផ្សាយនៅពេលណាមួយ ដែលជាការចាប់ផ្តើមនៃទីផ្សារបំណុល និងជាមូលដ្ឋានសម្រាប់ការបោះផ្សាយមូលបត្រឯកជន។

# ៦.៤. ទិសដៅគោលនយោបាយសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ (២/៤)

២. បន្តប្រើប្រាស់ឥណទានសម្បទានសម្រាប់ហិរញ្ញប្បទានលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងវិស័យបង្កើនផលិតភាពផលិតកម្ម សំដៅទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង។

៣. បន្តពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ក្របខ័ណ្ឌហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូ រវាងរដ្ឋនិងឯកជន (PPP)។

៤. បន្តទទួលតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់។

៥. បន្តអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់ក្នុងវិស័យសំខាន់ៗ សំដៅសម្រេចបាននូវចីរភាពកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម ក្នុងរង្វង់ **៧ ភាគរយ** និងកំណើនចំណូលថវិកាជាតិក្នុងរង្វង់ជាមធ្យម ០,៥ **ពិន្ទុភាគរយ** នៃ ផសស ក្នុងមួយឆ្នាំ។

៦. បន្តអនុវត្តគោលការណ៍មជ្ឈការក្នុងការគ្រប់គ្រងបំណុលសាធារណៈ។

# ៦.៤. វិធានការគោលនយោបាយសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ: ២០១៥ - ២០១៨ (៣/៤)

**៧.** បន្តពង្រឹងការកៀរគរហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានពីប្រភពផ្សេងទៀតសម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប។

**៨.** បន្តពង្រឹងការតាមដាន និងត្រួតពិនិត្យលើហានិភ័យបំណុលពាក់ព័ន្ធ ជាពិសេស ហានិភ័យនៃកាតព្វកិច្ចបំណុលដោយថាហេតុដែលអាចកើតចេញ ពីការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) និង ពីវិស័យធនាគារនិងហិរញ្ញវត្ថុ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការគន្លឹះបន្ថែម ដូចខាងក្រោម៖

- ធានាទូទាត់គម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) មិនឱ្យលើសពី **៤ ភាគរយ នៃ ផសស** ដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន។
- វិភាជថវិកា ក្នុងរង្វង់ **៥ ភាគរយ** នៃសេវាបំណុលសរុបប្រចាំឆ្នាំ ដើម្បីបង្កើតជាមូលនិធិបម្រុង (Contingency Fund) សម្រាប់ត្រៀមដោះស្រាយការធានាទូទាត់របស់រដ្ឋលើគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP)។

# ៦.៤. ទិសដៅការគោលនយោបាយសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ២០១៥ - ២០១៨ (៤/៤)

- ធនាគារជាតិនៃកម្ពុជា នឹងសិក្សាគ្រប់ជ្រុងជ្រោយលើហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពីវិស័យធនាគារនិងហិរញ្ញវត្ថុ ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈពិភាក្សា និងស្នើវិធានការដោះស្រាយក្នុងករណីចាំបាច់។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងនាំមុខក្នុងការរៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ការគ្រប់គ្រងបំណុលរួមរបស់ជាតិទាំងមូល ឱ្យគ្របដណ្តប់ទាំងបំណុលរបស់វិស័យឯកជន ជាពិសេស បំណុលក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ។

៩. បន្តពង្រឹងការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន ពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ឱ្យមានប្រសិទ្ធភាពខ្ពស់៕